អង្គភាពសវនកម្មផ្ទៃក្នុង
INTERNAL AUDIT UNIT

អត្ថបទប្រចាំខែ

លេខ ៣៤/២៤ ចេញផ្សាយ ខែតុលា ឆ្នាំ២០២៤

# ការគ្រប់គ្រងសាច់ប្រាក់

ដើម្បីឱ្យអង្គភាពមួយអាចដំណើរការបានជោគជ័យក្នុងរយៈពេលវែង អង្គភាពនោះចាំបាច់ត្រូវមានប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់មួយដ៏រឹងមាំ។ ការគ្រប់គ្រងសាច់ប្រាក់ជាផ្នែកមួយដ៏សំខាន់ដែលអង្គភាពត្រូវយកចិត្តទុកដាក់។ ការគ្រប់គ្រងសាច់ប្រាក់បានល្អជាផ្នែកមួយគាំទ្រដល់ការអនុវត្តកិច្ចការហិរញ្ញវត្ថុរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

**១. តើអ្វីទៅជាការគ្រប់គ្រងសាច់ប្រាក់?**

យោងតាមសៀវភៅឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុដែលដាក់ចេញឱ្យប្រើប្រាស់ដោយអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ. ស. ហ.** បានកំណត់នូវនិយមន័យ**ការគ្រប់គ្រងសាច់ប្រាក់**ថាជាការរៀបចំផែនការ ការចាត់ចែងសាច់ប្រាក់ចូល និងសាច់ប្រាក់ចេញ និងស្វែងរកដំណោះស្រាយឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលាជៀសផុតពីហានិភ័យនានា ពេលមានបញ្ហាវិបត្តិហិរញ្ញវត្ថុកើតឡើង។ ការគ្រប់គ្រងសាច់ប្រាក់ដើរតួនាទីយ៉ាងសំខាន់ក្នុងផ្នែកហិរញ្ញវត្ថុ ព្រោះការគ្រប់គ្រងសាច់ប្រាក់បានត្រឹមត្រូវនឹងជួយផ្តល់ភាពគ្រប់គ្រាន់នៃទំហំសាច់ប្រាក់ក្នុងពេលមានតម្រូវការចាំបាច់ណាមួយផងដែរ។

**២. គោលបំណង និងសារៈសំខាន់ការគ្រប់គ្រងសាច់ប្រាក់**

គោលបំណងនៃការគ្រប់គ្រងសាច់ប្រាក់ គឺការគ្រប់គ្រងលំហូរសាច់ប្រាក់ចូល និងលំហូរសាច់ប្រាក់ចេញ ដោយត្រូវធានាបានថាលំហូរសាច់ប្រាក់ចេញមានកម្រិតទាបជាងលំហូរសាច់ប្រាក់ចូលដែលជួយលើកកម្ពស់ស្ថេរភាពហិរញ្ញវត្ថុរបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាព និងដឹងអំពីបម្រែបម្រួលស្ថានភាពសាច់ប្រាក់ ទាំងលំហូរសាច់ប្រាក់ចេញ និងលំហូរសាច់ប្រាក់ចូលក្នុងការិយបរិច្ឆេទជាក់លាក់ណាមួយរបស់ស្ថាប័ន។



- **សារៈសំខាន់នៃការគ្រប់គ្រងសាច់ប្រាក់រួមមាន៖**

**ក. ការបង្កើតនូវគម្រោងផែនការ និងការសម្រេចចិត្ត៖** ការគ្រប់គ្រងលំហូរសាច់ប្រាក់បានល្អ ជាកត្តាជំរុញទឹកចិត្តដល់គ្រប់ស្ថាប័នឱ្យបង្កើតនូវយុទ្ធសាស្ត្រនៅក្នុងរយៈពេលខ្លី ឬវែង ដើម្បីអភិវឌ្ឍន៍ស្ថាប័ននាពេលអនាគត។

**ខ. ការបង្ហាញពីទិសដៅជាក់លាក់នៃលំហូរសាច់ប្រាក់៖** ការយល់ដឹងអំពីស្ថានភាពជាក់ស្តែងនៃចំណូល និងចំណាយផ្តល់ភាពងាយស្រួលក្នុងការកាត់បន្ថយ ឬបង្កើនការចំណាយលើផ្នែកណាមួយដែលមានភាពចាំបាច់សម្រាប់ប្រតិបត្តិការរបស់ស្ថាប័ន។

**គ. ការការពារ និងបង្កើនទំនាក់ទំនងជាមួយដៃគូ÷** ភាពវិជ្ជមានរបស់របាយការណ៍លំហូរសាច់ប្រាក់នៃប្រតិបត្តិការរបស់ស្ថាប័នអាចជាកត្តាមួយជំរុញឱ្យដៃគូសហការផ្សេងៗមានការចាប់អារម្មណ៍ និងបង្កើនទំនុកចិត្តនៅក្នុងការសហការជាមួយស្ថាប័ន។

**ឃ. ការយល់ច្បាស់ពីពេលវេលាដើម្បីពង្រីកស្ថាប័ន÷** ការយល់ដឹងអំពីលំហូរសាច់ប្រាក់ជាមួយនឹងភាពជាក់លាក់នៃរបាយការណ៍លំហូរសាច់ប្រាក់ នឹងជួយស្ថាប័នឱ្យដឹងអំពីស្ថានភាពជាក់ស្តែងរបស់ស្ថាប័ន ដឹងអំពីពេលវេលា និងភាពត្រឹមត្រូវ ក្នុងការពង្រីកប្រតិបត្តិការរបស់ស្ថាប័ន។



## ៤. ការសន្និដ្ឋាន

សរុបមកការគ្រប់គ្រងសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាពគឺមានសារៈសំខាន់ចំពោះសុខភាពហិរញ្ញវត្ថុ និងប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ស្ថាប័ន ដើម្បីធានាថាស្ថាប័នមានសាច់ប្រាក់គ្រប់គ្រាន់ដើម្បីបំពេញតម្រូវការរបស់ខ្លួន។ លើសពីនេះតាមរយៈការរក្សាលំហូរសាច់ប្រាក់ឱ្យមានតុល្យភាពធ្វើឱ្យស្ថាប័នមានឱកាសច្រើនក្នុងការវិនិយោគដើម្បីទទួលបានប្រាក់ចំណេញនិយាយចំពោះស្ថាប័នដែលស្វែងរកប្រាក់ចំណេញ។ ការអនុវត្តការគ្រប់គ្រងសាច់ប្រាក់បានល្អនាំឱ្យមានភាពប្រសើរឡើងក្នុងការសម្រេចចិត្ត បង្កើនស្ថិរភាពហិរញ្ញវត្ថុ និងប្រសិទ្ធភាពប្រតិបត្តិការការងារ។

**អត្ថបទ÷** លោក **សោភា សុភីស័ក**

**ឯកសារយោង÷** *សៀវភៅឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ. ស. ហ.***



ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ. ស. ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។